USAID
ជំនួយពីពលរដ្ឋអាមេរិក

អង្គការអប់រំពិភពលោក
WORLD EDUCATION

# គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជា (IBEC) Project

ព្រឹត្តិបត្រព័ត៌មានប្រចាំត្រីមាស

ខែ មីនា ២០១១ លេខ ៩

## សេចក្ដីសង្ខេបគម្រោង IBEC

- មានរយៈពេល ៥ ឆ្នាំ ចាប់ពី ខែ តុលា ២០០៩ ដល់ ខែ កញ្ញា ២០១៤
- សកម្មភាពប្រតិបត្តិមាននៅក្នុង ខេត្ត ៣ គឺ ខេត្តកំពង់ចាម ខេត្តក្រចេះ និងខេត្តសៀមរាប
- មានថវិកាចំនួន ១០ លាន ដុល្លាសហរដ្ឋអាមេរិក
- ជួយដល់សាលាបឋមសិក្សា ចំនួន ២០២ សាលា និងសាលា មធ្យមសិក្សាបឋមភូមិ ចំនួន ១០១ សាលា

## ដៃគូគម្រោង IBEC

គម្រោងកែលម្អអប់រំកម្រិតមូលដ្ឋាននៅកម្ពុជាបានទទួលថវិកាពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។ គម្រោងនេះត្រូវបានប្រតិបត្តិដោយអង្គការអប់រំពិភពលោក (World Education) ដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយអង្គការសកម្មភាពសម្រាប់បឋមសិក្សានៅកម្ពុជា (KAPE) និងសហប្រតិបត្តិការជាមួយក្រសួងអប់រំយុវជន និងកីឡា (MoEYS) ។

*ដៃគូក្នុងស្រុកមានអង្គការ :*
WCRD, BSDA, NEP និង EDA

*ដៃគូអន្តរជាតិមានអង្គការ :*
Equal Access និងវិទ្យាស្ថានស្រាវជ្រាវសហរដ្ឋអាមេរិក (AIR)

## ការចាប់ផ្ដើមគម្រោង IBEC នៅឆ្នាំទី២ ដោយមានការពង្រីកសំខាន់ៗនៅខេត្តសៀមរាប

ចាប់ពីខែតុលា ដល់ខែធ្នូឆ្នាំ ២០១០ នាត្រីមាសនេះ គឺជាការចាប់ផ្ដើមអនុវត្តគម្រោង IBECនៅឆ្នាំទី២ ហើយ ក៏ស្របគ្នានឹងការចាប់ផ្ដើមបវេសនកាលឆ្នាំថ្មីនៅកម្ពុជាផងដែរ ។ យោងទៅលើសមិទ្ធផលដែលទទួលបានយ៉ាងជោគជ័យនៅឆ្នាំទីមួយ គម្រោង IBEC បានចាប់ផ្ដើមនៅត្រីមាសនេះដើម្បីពង្រីកសកម្មភាពគម្រោងសំខាន់ៗនៅខេត្តសៀមរាប ។ គម្រោង IBECបានចាប់ផ្ដើមជួយដល់សាលាបឋមសិក្សាចំនួន ៥២ នៅខេត្តសៀមរាប ដែលពីមុនបានជួយតែសាលាមធ្យមសិក្សាប៉ុណ្ណោះ ។ លើសពីនេះផងដែរ មានសាលាបឋមសិក្សាចំនួន ១១ ផ្សេងទៀតត្រូវបានបញ្ចូលបន្ថែមនៅខេត្តកំពង់ចាម ហើយចំនួន ៣ នៅខេត្តក្រចេះ ដែលសរុបសាលាទាំងអស់នៅក្នុងគម្រោងមានចំនួន ៣០៣ (សាលាបឋមសិក្សាចំនួន ២០២ និងមធ្យមសិក្សាចំនួន ១០១) ។ ដោយមានកិច្ចសហការជាមួយក្រុមការងារថ្នាក់ខេត្តនៅតាមខេត្តនីមួយៗ ការជ្រើសរើសសាលាបឋមសិក្សាថ្មីជាចុងក្រោយត្រូវបានបញ្ចប់ហើយ ។ ដំណើរការជ្រើសរើសសាលាបង្ហាញឱ្យឃើញថាវាជា លក្ខណៈប្រជាសាស្ត្រចម្រុះយ៉ាងសំខាន់ ដែលមានទាំងទីក្រុង ជនបទ និងសាលានៅតាមតំបន់ដាច់ស្រយាលផងដែរ ។

ការកើនឡើងចំនួនសាលារៀនដែលបានជួយដោយគម្រោង IBEC និងចំនួនកុមារកម្ពុជាដែលទទួលបានផលពីសកម្មភាពអនុវត្តគម្រោងក៏បានកើនឡើងស្របគ្នាផងដែរ ។ ក្រុមការងាររបស់គម្រោង IBECខាងផ្នែកតាមដាន និងវាយតម្លៃបានប្រមូលស្ថិតិចំនួនសិស្ស ដែលទទួលបានរបាយការណ៍ពីសាលាទាំងអស់សម្រាប់ឆ្នាំសិក្សាថ្មី ។ ជាសរុប ការចុះឈ្មោះចូលរៀននៅតាមសាលាគោលដៅឥឡូវនេះមានចំនួនសិស្សរហូតដល់ ១៣៥ ៤៩៥ ដែលមានការកើនឡើង ៤៣% លើសឆ្នាំទី១ ។

សិស្សទាំងអស់នេះកំពុងទទួលបានប្រយោជន៍ពីសកម្មភាពកែលម្អសាលារៀនដោយមានជំនួយឧបត្ថម្ភចំនួន ៩៣ ៩៨១ ដុល្លា (ដែលមិនរាប់បញ្ចូលទៅក្នុងអាហារូបករណ៍ឡើយ) ចែកជូនដល់សាលាបឋមសិក្សាក្នុងគម្រោង IBEC សម្រាប់ឆ្នាំសិក្សា ២០១០-២០១១ ហើយក៏បានជួយឧបត្ថម្ភទៅដល់សាលាមធ្យមសិក្សាគោលដៅចំនួន ១៦២ ៨៤៩ ដុល្លាផងដែរ ដើម្បីអនុវត្តលើសកម្មភាពផែនការកែលម្អសាលារៀន ។ នៅកម្រិតបឋមសិក្សា ថវិកានេះគឺកំពុងគាំទ្រដល់សកម្មភាពចំនួន ៤៩ ដោយគ្របដណ្ដប់ទៅលើសមាសភាគទាំង៦នៃសាលាកុមារមេត្រី ។ ចំពោះសាលាកម្រិតមធ្យមសិក្សាក្នុងគោលដៅបានសំណូមពរឱ្យជួយដល់សកម្មភាពផ្សេងៗទៀត ដែលមានចំនួន ៧៥ ទាំងនេះគឺផ្អែកទៅលើការវិភាគបញ្ហា និងសេចក្ដីត្រូវការរបស់ពួកគេ ។



*ព្រឹត្តិបត្រព័ត៌មាននេះអាចផលិតទៅបានដោយមានការឧបត្ថម្ភ ក្រោមជំនួយសប្បុរសធម៌ពីពលរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។*
*រាល់ខ្លឹមសារនៅក្នុងព្រឹត្តិបត្រនេះ ជាការទទួលខុសត្រូវរបស់អង្គការអប់រំពិភពលោក និងមិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ USAID រឺរដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។*
*ការិយាល័យអង្គការអប់រំពិភពលោក : ផ្ទះលេខ ២០ ផ្លូវ ២២២ ភ្នំពេញ កម្ពុជា ទូរស័ព្ទលេខ ៨៥៥-២៣-២១ ៦៨ ៥៤ ទូរសារលេខ ២១៨ ៣៦៩* E-mail: worldedcam@worlded.org.kh

# សមាសភាគ១ : ការកសាងសមត្ថភាពរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក និងការស្វែងរកការគាំទ្រសម្រាប់និរន្តរភាព

សកម្មភាពកសាងសមត្ថភាពនៃគម្រោង IBEC ក្នុងត្រីមាសនេះផ្តោតលើសាលារៀន ដៃគូការងារក្នុងស្រុក សាលាបំភ្លឺផ្លូវ និងគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ (CEFACs) ដែលជាអ្នកទទួលខុសត្រូវលើការងារសាលារៀនដើម្បីជំរុញការចូលរៀនឱ្យរិតតែងាយស្រួលនិងប្រសើរឡើង។

គោលបំណងគម្រោង IBEC គឺធ្វើយ៉ាងណាឱ្យគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំមានការទទួលខុសត្រូវលើតួនាទីរបស់ខ្លួន ឬអាចអនុវត្តបានលើវិស័យអប់រំនៅតាមមូលដ្ឋាន។ (CEFACs) ត្រូវបានបង្កើតឡើងនៅឆ្នាំ២០០៣ប៉ុន្តែមានករណីច្រើនដោយពួកគេពុំបានអនុវត្តឱ្យពេញលេញនៅឡើយទេ។ ភារកិច្ចតួនាទី និងការទទួលខុសត្រូវ ជួលកាលមិនច្បាស់លាស់ ហើយជួនកាលមានការងារត្រួតគ្នាជាមួយក្រុមការងារផ្សេងទៀត (ឧទាហរណ៍ ដូចជា គណៈកម្មាការទ្រទ្រង់សាលារៀន)។ ការងារនៃគម្រោង IBEC គឺជួយដល់ការទទួលខុសត្រូវបស់ CEFACs លើការងារដែលត្រូវផ្សារភ្ជាប់ជាមួយយន្តការសហការនៃក្រុមប្រឹក្សាឃុំ ដោយពង្រឹងធ្វើឱ្យក្រុមការងារទាំងពីរនេះមានសមត្ថភាពគ្រប់គ្រង និងជួយដល់កិច្ចសហប្រតិបត្តការរបស់គេ។ ការពង្រឹងសកម្មភាពគឺផ្តោតទៅលើការកែលម្អចំណេះដឹងបច្ចេកទេសអប់រំ ធ្វើ យ៉ាងណាឱ្យស្របតាមការអនុវត្តន៏ជំនាញបច្ចេកទេសដើម្បីធ្វើឱ្យគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំកាន់តែទទួលបាននូវសមិទ្ធិផលលើតួនាទីការងារក្នុងរចនាសម្ព័ន្ធក្រុមប្រឹក្សាឃុំ។

នៅអំឡុងនៃត្រីមាសនេះផងដែរមានគណៈកម្មការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំថ្មីចំនួន ១២ ត្រូវបានកំណត់បន្ថែមទៅលើ CEFACs ១២ ដែលមានស្រាប់។ កាលពី ខែធ្នូ ២០១០ គណៈកម្មការ៥ក្នុងចំណោមគណៈកម្មការទាំងនោះបានទទួលការ បណ្តុះបណ្តាលតម្រង់ទិសជាលើកដំបូង លើការទទួលខុសត្រូវនូវតួនាទីរបស់ CEFACs និងគោលការសំខាន់ៗរបស់ ក្រសួងដើម្បីអនុវត្ត។ ក្រោយពីបានរំលឹកនូវវគ្គបណ្តុះបណ្តាលមុនៗ បុគ្គលិកគម្រោង IBEC បានចាប់ផ្តើមពិនិត្យសើររើនូវមាតិការមេរៀនបណ្តុះបណ្តាល ដែលនឹងត្រូវយកមកប្រើសម្រាប់វគ្គបណ្តុះបណ្តាលCEFACs នៅពេលខាងមុខ។ ដំណើរការនៃការរៀបចំឯកសារលើកនេះបានចាប់ផ្តើមតាំងពីខែធ្នូមកម្លេះ នឹងត្រូវបានចប់រួចរាល់នៅក្នុងត្រីមាសបន្ទាប់។

ដើម្បីឱ្យការងារលើផ្នែកកសាងសមត្ថភាពនេះមានដំណើរការទៅមុខយ៉ាងរលូន បុគ្គលិកផ្នែកនេះបានខិតខំព្យាយាមលើកទឹកចិត្តជំរុញឱ្យថ្នាក់ដឹក នាំស្រុកឱ្យចេញនូវលិខិតចាត់តាំងជាផ្លូវការសម្រាប់សមាជិករបស់គណៈកម្មាការអប់រំសម្រាប់ទាំងអស់គ្នាថ្នាក់ឃុំ។ ដោយមានលខិតនេះបាន ធ្វើឱ្យប្រតិបត្តិកាន់តែមានប្រសិទ្ធិភាពជាមួយគណៈកម្មការទាំងនោះ។ ចំពោះការឆ្លើយតប ពីថ្នាក់ដឹកនាំស្រុក រហូតមកដល់ពេលនេះគឺមានការគាំទ្រយ៉ាងខ្លាំង ហើយចំនួនស្រុកសរុបទាំងអស់មានរហូតដល់ ៣១ ដែលចំនួន ១២ស្រុកហើយដែលបានចេញនូវលិខិតតែងតាំងរួច។



## ការអប់រំបញ្ច្រាបតាមរយៈកម្មវិធីវិទ្យុ

ការចាប់ផ្តើមឆ្នាំសិក្សាថ្មីនេះ គម្រោង IBEC និង Equal Access បានចាប់ផ្តើមដំណើរការផលិតកម្មវិធីវិទ្យុ ស្តីពីបំណិនជីវិត ដោយមានការពិនិត្យថែមថយលើសំណូមពរពីអ្នកស្តាប់ ជាពិសេសពីក្រុមអ្នកស្តាប់ដែលបានបើកស្តាប់កម្មវិធីមុនៗ។ កម្រងរឿងចំនួន១០នៃកម្មវិធីបំណិនជីវិតត្រូវបានពិភាក្សា និងឯកភាព ហើយកម្មវិធីវិទ្យុដំបូងបានចាក់ផ្សាយនូវរាល់ប្រធានបទទាំងនោះកាលពីថ្ងៃទី១៨ខែវិច្ឆិកាឆ្នាំ២០១០នៅខេត្តកំពង់ចាមដោយចាក់ផ្សាយពីរលើក។ ការឱ្យយោបល់លើការចាក់ផ្សាយនេះអាចជួយពង្រឹងដល់កម្មវិធីបំណិនជីវិតដែលចាក់ផ្សាយតាមវិទ្យុដែលមានឈ្មោះថា We Can Do It ហើយគោលដៅសម្រាប់អ្នកស្តាប់គឺជាសិស្សសាលាមធ្យមសិក្សាបឋមភូមិ។ ផ្អែកលើមតិយោបល់ជាវិជ្ជមានពីសមាជិកអ្នកស្តាប់ ពិធីករ និងពិធីការនីគឺ ភារម្យ និងសុធា នឹងបន្តការងារនេះជាបន្តទៀតសម្រាប់កម្មវិធីនៅឆ្នាំទីពីរ។ ទ្រង់ទ្រាយបែបបទនៃកម្មវិធីនេះ ជាទូទៅទទួលបាននូវការកោតសរសើរយ៉ាងខ្ពស់ ហើយការងារក៏បន្តនៅឆ្នាំនេះទៀតដែរ។

ក្រុមអ្នកស្តាប់ និងសន្ទនា១០ផ្សេងទៀតត្រូវបានបង្កើតឡើងនៅត្រីមាសនេះ ហើយបច្ចុប្បន្នមានក្លឹបអ្នកស្តាប់ចំនួន៣០ដែលកំពុងដឹកនាំការប្រជុំជាទៀងទាត់រាល់ខែ។ នៅអំឡុងនៃត្រីមាសនេះ ក្រុមអ្នកស្តាប់ និងសន្ទនាបានដឹកនាំការប្រជុំ ៣២លើកហើយដែលមានអ្នកចូលរួមចំនួន៧៨១នាក់។ ជាមធ្យមម្តងៗមានសិស្សសាលាចំនួន២៤នាក់ចូលរួមប្រជុំ គិតចាប់ពីត្រីមាសមុន មានការកើនឡើង ៣៣ ភាគរយ។ ការកើននេះដោយសារមានការលើកទឹកចិត្តឱ្យឱ្យពុកម្តាយ និងសមាជិកសហគមន៏ផ្សេងៗទៀត គឺមិនត្រឹមតែសិស្សប៉ុណ្ណោះទេឱ្យចូលរួមប្រជុំពិភាក្សាលើការស្តាប់ និងសន្ទនានេះ។

ក្លឹបស្តាប់គឺជាមធ្យោបាយដែលធ្វើយ៉ាងណាឱ្យអ្នកស្តាប់ទាំងអស់អាចឆ្លើយឆ្លងទៅវិញទៅមកជាមួយកម្មវិធីវិទ្យុដែលមានឈ្មោះថា We Can Do It ។ អ្នកស្តាប់ទូទៅអាចផ្ញើរមតិយោលបល់របស់គេទៅអ្នកផលិតកម្មវិធីតាមរយៈសំបុត្រ និង SMS ជាដើម។ គិតចាប់ពីខែតុលារហូតដល់ខែធ្នូ ឆ្នាំ ២០១០ អង្គការ Equal Access បានទទួលសំបុត្រចំនួន ៤៥៥ និង SMS ចំនួន ២៦៧ ហើយ។

**ប្រធានបទដែលបានចាក់ផ្សាយតាមកម្មវិធីវិទ្យុ (វិច្ឆិកា-ធ្នូ ២០១០)**

- ការសិក្សាភាសាបរទេស
- ការរៀបចំទិសដៅនិងគោលបំណងនាពេលអនាគត
- ការផ្លាស់ប្តូរដែលកើតមានឡើងនៅដំណាក់កាលអាយុពេញវ័យ
- ការគ្រប់គ្រងលុយកាក់

មតិយោបល់ដែលទទួលបានពីអ្នកស្តាប់ បង្ហាញឱ្យឃើញថា កម្មវិធីវិទ្យុនេះ ពិតជាមានសារៈសំខាន់ ហើយក៏ទាក់ទងទៅនឹងជីវិតប្រចាំថ្ងៃរបស់ពួកគេផងដែរ។ អ្នកឆ្លើយឆ្លងទាំងនោះបានលើកឡើងថា ចំពោះសាច់រឿងស្តីពីការរៀបចំគោលដៅបំរែបំរួលរាងកាយ ការគ្រប់គ្រងលុយកាក់ និងសារៈសំខាន់នៃការរៀនភាសាបរទេស គឺពិតជាមានប្រយោជន៏សម្រាប់ពួកគេ។ **រៀវ លីហួ** អ្នកសម្របសម្រួលក្រុមស្តាប់ និងសន្ទនា មកពីវិទ្យាល័យ ហ៊ុន សែន គរបានសរសេរផ្ញើរមកថា "ខ្ញុំមានអារម្មណ៏យល់ឃើញថាឃុតឆាកនៃសាច់រឿងស្តីអំពីសារៈសំខាន់នៃការរៀនភាសាបរទេស គឺពិតជាល្អ និងមានសារៈសំខាន់សម្រាប់ខ្ញុំណាស់ ពីព្រោះវារឹតតែធ្វើឱ្យខ្ញុំមានការតាំងចិត្តក្នុងការរៀនភាសា" គាត់បានបន្ថែមថា "មានមនុស្សកាន់តែច្រើនឡើងៗចូលរួមក្រុមស្តាប់របស់ខ្ញុំ" នេះជាការបង្ហាញឱ្យឃើញថាសារៈសំខាន់នៃក្រុមអ្នកស្តាប់នៅសាលារបស់គាត់កាន់តែមានប្រជាប្រិយភាពឡើងជាលំដាប់។

## សមាសភាគ ២ : សមធម៌ក្នុងការទទួលបានការអប់រំច្រើនជាងមុន

*អំណោយសាលារៀន ដែលត្រូវសម្រេចចិត្តដោយអ្នកពាក់ព័ន្ធ*

ការចាប់ផ្តើមបរវេសនកាល និងការអនុវត្តគម្រោង IBEC ឆ្នាំថ្មីនេះ គឺជាត្រីមាសដែលរវល់ខ្លាំង ដោយ IBEC មានការបែងចែកអាហារូបករណ៍សម្រាប់ឆ្នាំសិក្សា ២០១០-២០១១ ហើយសាលាគោលដៅទាំង ៣០៣ បានបញ្ចប់ផែនការកែលម្អសាលារៀនរបស់គេផងដែរ ។

**អ្នកដែលពាក់ព័ន្ធនឹងគម្រោង IBEC បានសម្រេចផ្តល់អាហារូបករណ៍ដល់កុមារដែលមានស្ថានភាពពិបាក ចំនួន ៣ ៩៤៧ នាក់ ដែលរៀននៅសាលាបឋមសិក្សា (៦០%ជានារី និង ៩%ជាកុមារជនជាតិភាគតិច) ហើយ ១ ៣២១ នាក់ជាសិស្សក្រីក្រ រៀននៅកម្រិតមធ្យមសិក្សា (៧២ % ជានារី និង ៧% ជាកុមារជនជាតិភាគតិច) ។** ចំនួនអាហារូបករណ៍នៃសាលាមធ្យមសិក្សាបានឱ្យឃើញថាមានការកើនឡើងចំនួន១០៨%ច្រើនជាងពីឆ្នាំមុនដែលមានអាហារូបករណ៍ផ្តល់ឱ្យត្រឹមតែ៦៣៩ប៉ុណ្ណោះ ។

គម្រោងក៏បានផ្តល់អាហារូបករណ៍ដល់គរុនិសិត្ស សាលាគរុកោសល្យនិងវិក្រឹតការខេត្ត (PTTC) ចំនួន ១១៥ នាក់ ដែលជាបេក្ខជនទទួលបានជោគជ័យជាអាទិភាពក្នុងការជ្រើសរើស មកពីឃុំដាច់ស្រយាល ដើម្បីកុំឱ្យខ្វះគ្រូ ។ ចំនួនសរុបនៃបេក្ខជន (PTTC) ដែលបានជួយនៅឆ្នាំនេះមាន ១១៥ នាក់ ជាគរុនិសិត្សថ្មីឆ្នាំទី១ ថែមពីលើនោះចំនួន៧២នាក់ជាគរុនិសិត្សឆ្នាំទី២ ។ ការឧបត្ថម្ភអាហារូបករណ៍មាន២៩ដុល្លាក្នុងមួយខែ សម្រាប់រយៈពេល៩ខែ ។ ចាប់តាំងពីដំណើរការនៃគម្រោងនេះមក មានគរុនិសិត្ស សាលាគរុកោសល្យ និងវិក្រឹតការខេត្តចំនួន២៥៦ នាក់ហើយដែលត្រូវបានជួយ ហើយ៩៦នាក់ក្នុងចំណោមពួកគេនោះត្រូវបានចាត់តាំងឱ្យទៅបង្រៀននៅតាមសាលាផ្សេងៗក្នុងឆ្នាំសិក្សាថ្មី ។

ស្របគ្នានឹងពេលវេលាចាប់ផ្តើមបរវេសនកាល គម្រោងកែលម្អសាលារៀនក៏ត្រូវបានបញ្ចប់រួចរាល់ជាស្ថាពរ ដែលមាន ៦១ កម្រង ក្នុងនោះមានសាលាបឋមសិក្សាដែលជាសាលាគោលដៅចំនួន ២០២ និងសាលាមធ្យមសិក្សាចំនួន ១០១ ។ **ការអនុមតិផែនការកែលម្អសាលារៀនត្រូវបានសម្រេចឡើង ដោយមានកិច្ចសហការណ៍យ៉ាងជិតស្និទ្ធិជាមួយក្រុមការងារថ្នាក់ខេត្ត ហើយនាំឱ្យទទួលបាននូវថវិកាជំនួយចំនួន ២៥៦ ៨៣១ ដុល្លា សម្រាប់សាលាគោលដៅចំនួន ៣០៣ ដែលបានកំណត់រួច ។**

ចំពោះសាលាថ្មីទទួលបានការបណ្តុះបណ្តាលបន្ថែមលើផែនការគោល នៃការប្រើប្រាស់កម្មវិធីរៀបចំផែនការសាលារៀនសមហេតុផល ដែលបានកំណត់នូវបញ្ហាគោលបំណង សកម្មភាពចំបងៗ និងសេចក្តីត្រូវការលើធនធានផ្សេងៗ ក៏ដូចជាឥទ្ធិពលពីកត្តាខាងក្រៅមកលើផែនការអនុវត្តជាដើម ។

នៅកម្រិតបឋមសិក្សា ការអនុវត្តន៍សកម្មភាពរួមមាន ការគាំទ្រដល់គណៈកម្មាការទ្រទ្រង់សាលារៀន ផែនទីសាលារៀន ប្រអប់សង្គ្រោះបន្ទាន់ និងការជួយដល់ក្រុមប្រឹក្សាកុមារ ។ នៅកម្រិតមធ្យមសិក្សា ការអនុវត្តសកម្មភាព រួមមានការជួយដល់ក្រុមប្រឹក្សាសិស្ស ការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំសម្រាប់នាយកសាលា ការអភិវឌ្ឍន៍បណ្ណាល័យ និងក្រុមប្រឹក្សាកុមារី ។



### រឿងជោគជ័យ

វិទ្យាល័យ ហ៊ុន សែន អូររាំងឪ គឺជាសាលាដ៏ធំមួយក្នុងចំណោមសាលាធំៗជាច្រើននៅខេត្តកំពង់ចាម សាលានេះមានសិស្សចំនួនប្រហែល ១ ៦៣៩ នាក់ (ស្រី៦៣៩) ហើយមានគ្រូចំនួន ៥៨ នាក់ ។ អាគារសិក្សានៃសាលានោះភាគច្រើនសង់តាមបែបផ្សេងៗគ្នាតាមសម័យកាល ដូចជាការសាងសង់មុនសង្គ្រាមស៊ីវិលនាឆ្នាំ១៩៧០ ហើយឥឡូវនេះវាចាស់ទ្រុឌទ្រោមទៅហើយ ។ ដោយការចុះឈ្មោះចូលរៀននៅកម្រិតមធ្យមសិក្សាកាន់តែមានចំនួនច្រើនឡើង នៅឆ្នាំនេះ សាលាត្រូវពឹងផ្អែកលើអាគារចាស់ៗទាំងអស់នោះហើយ ។ លោកនាយកសាលាបានយកដៃចង្អុលទៅកាន់អាគារមួយ ព្រមទាំងមានប្រសាសន៍ថា" វាមិនមានសុវត្ថិភាពសម្រាប់សិស្សដែលរៀននៅក្នុងអាគារបែបនេះទេ ហើយយើងក៏មិនអាចរៀបចំបរិស្ថានរៀនសូត្រឱ្យបានល្អដែរព្រោះយើងនៅមានការខ្វះខាតថ្នាក់រៀន ទោះបីជាយើងខំប្រឹងប្រើប្រាស់ធនធាន ដែលមានទាំងនោះយ៉ាងណាក៏ដោយ ។

នៅឆ្នាំ ២០០៩ គម្រោង IBEC បានជ្រើសរើសវិទ្យាល័យអូររាំងឪជាសាលាគោលដៅមួយ ។ ក្រោយមកសាលានោះបានបង្ហាញឱ្យឃើញថាមានការរីកចំរើនទៅមុខនៅឆ្នាំទីមួយ ហើយបន្ទាប់មកក៏ត្រូវបានចំណាត់ថ្នាក់ឱ្យជាប្រភេទទី១ (Tier I) នៅឆ្នាំ ២០១០ ។ នៅពេលដែលសាលានោះចាប់ដំណើរការ ការរៀបចំផែនការសាលារៀន វាជាការបញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថាសាលាមានសមត្ថភាពក្នុងការអនុវត្តន៏នូវអ្វីដែលជាសក្តានុពលភាពដែលសង្ឃឹមថាសាលាអាចធ្វើបាន ។

ដោយមានការឧបត្ថម្ភថវិកាពី USAID គម្រោងអនុវត្តការងារបានឯកភាពធ្វើយ៉ាងណាឱ្យបានប្រសើរឡើងលើការរៀបចំហេដ្ឋារចនាសម្ព័ន្ធ រួមមានការប្រើប្រាស់កុំព្យូទ័រដោយថាមពលព្រះអាទិត្យ បន្ទប់ពិសោធន៏វិទ្យាសាស្ត្រ ការតុបតែងបណ្ណាល័យ និងបន្ទប់សម្រាប់សកម្មភាពបំណិនជីវិត ។ សាលាបានធ្វើបដិការ ដោយមានវិភាគទានថវិកាយ៉ាងច្រើននូវធនធានហិរញ្ញវត្ថុចំនួន(១៣០០ដុល្លា) ហើយដោយមានការជ្រោមជ្រែងពីលោកគ្រូអ្នកគ្រូ ការរៀបចំចាត់ចែងដំណើរការបន្ទប់កុំព្យូទ័រក៏បានធ្វើឡើង ។ នេះជាឧទាហរណ៍មួយនៃការចូលរួមពង្រឹង ដើម្បីឱ្យសម្រេចបាននូវក្តីប្រាថ្នាចង់បានរបស់យើង ។ សាលាទទួលជោគជ័យលើការរៀបចំ ជួសជុលអាគារសិក្សាពីរ ដោយមានការជួយឧបត្ថម្ភពីគម្រោង និងសហគមន៏ស្របពេលជាមួយគ្នានោះក៏មានការពង្រីកបន្ថែមបន្ទប់រៀន ដែលជាការចាំបាច់ចំនួន ៨ ទៀត ព្រមទាំងមានការកែលម្អច្រើនទៀត ដើម្បីសម្រួលដល់ការសិក្សា ។ ដោយមានដំណើរការទៅមុខយ៉ាងរលូននោះ សាលាបានរៀបចំ ចាត់ចែងលើការតប្រព័ន្ធទឹកខ្វាត់ខ្វែង រួមមានសម្រាប់ស្រោចផ្កា និងបាសាំងទឹកដែលជាអំណោយពីឧបការីជននៅមូលដ្ឋាន ។ សាច់រឿងនិយាយពីវិទ្យាល័យអូររាំងឪនេះជាភស្តុតាងបង្ហាញឱ្យឃើញថាវាជាកម្លាំងចលករក្នុងការធ្វើដំណើរទៅមុខរបស់គម្រោង IBEC និងសូមឱ្យអ្នកដែលពាក់ព័ន្ធទាំងអស់រៀបចំការអភិវឌ្ឍន៍កម្មវិធីតាមបែបពីក្រោមឡើងទៅលើ ។







## សមាសភាគ ៣ ៖ កែលម្អការគ្រប់គ្រងសាលារៀន និងការចូលរួមពីសហគមន៍

សកម្មភាពសម្រេចបានដែលគួរឱ្យកត់សំគាល់របស់ IBEC នៅត្រីមាសនេះ ជាបឋមគឺគម្រោងមានការរៀបចំនូវវគ្គបំប៉នភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀន(SMLTC) ។ នេះជាដំណើរការនៃការបណ្តុះបណ្តាលជាគោលសំខាន់ ដែលគាំទ្រ និងបង្ហាញឱ្យឃើញនូវក្តីសង្ឃឹមរបស់គម្រោង ដែលធ្វើឱ្យអ្នកគ្រប់គ្រងសាលារៀនទទួលបាននូវចំណេះដឹងជាចាំបាច់ដើម្បីរៀបចំវិនិយោគលើវិស័យអប់រំធ្វើឡើងដោយ USAID បន្ទាប់ពីសេចក្តីសន្និដ្ឋានរួមរបស់គម្រោង ។ ការប្រើប្រាស់ក្រុមគ្រូបង្គោលចំនួន ៣២នាក់ដែលជ្រើសរើសបានមកពីបុគ្គលិកមូលដ្ឋានរដ្ឋាភិបាល ។ គម្រោង IBEC បានបណ្តុះបណ្តាលបុគ្គលិកទីចាត់ការសាលារៀនចំនួន ៥២១ នាក់ រួមមាននាយកសាលា លេខាធិការ និងបណ្ណារក្សដែលមកពីសាលាបឋមសិក្សា និងធ្យមសិក្សាបឋមភូមិទូទាំងខេត្ត ។

ខ្លឹមសារមាតិការនៃដំណើរការសិក្ខាសាលានេះគឺចំរាញ់ជ្រើសរើសយកចេញមកពីគម្រោងទ្រទ្រង់វិស័យអប់រំនៅកម្ពុជា ជាពិសេសគឺគោរពតាមគោលការភាពជាអ្នកដឹកនាំ ដូចជាការរៀបចំនូវទស្សនវិស័យ អត្ថន័យនៃភាពជាអ្នកដឹកនាំ និងការស្តែងចេញឱ្យឃើញនូវទស្សនៈ ដែលមានទាំងឡាយ ។ សិក្ខាសាលាក៏បានរៀបចំនូវសេចក្តីសង្ខេបស្តីពីគោលការនៃការគ្រប់គ្រង ដូចជាការធ្វើផែនការ ការបែងចែក កំនត់ពេលវេលា និងជំនាញចាត់ចែងផ្សេងៗទៀត ។ ការរៀចំនេះ គឺពិតជាជួយដល់ដំណើរការរៀបចំមេរៀន និងកិច្ចការល្អៗដនៃទៀតដែលមានស្រាប់ពីមុន និងការកែលម្អដើម្បីអនុវត្តបន្តទៅមុខទៀត ។

សិក្ខាសាលាស្តីពីភាពជាអ្នកដឹកនាំ និងការគ្រប់គ្រងសាលារៀននេះគឺធ្វើឡើងសម្រាប់រដ្ឋបាលសាលារៀន ដោយចំបាច់ត្រូវបំពេញនូវគម្រង លំហាត់ និងកិច្ចការផ្សេងៗទៀត សម្រាប់អ្នកដែលចូលរួមទាំងឡាយ ក្នុងរយះពេលសិក្ខាសាលានេះរហូតដល់សិក្ខាសាលាបន្ទាប់នៅខែមករា ២០១១។ សិក្ខាកាមទាំងអស់មានសិទ្ធិជ្រើសរើសកិច្ចការជាស្នូលមួយ ។ កិច្ចការទាំងនោះរួមមាន ការអភិវឌ្ឍន៍នូវទស្សនវិស័យសាលារៀន ការអនុវត្តន៍នូវអ្វីដែលយល់ឃើញ ការកែលម្អលើការប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមកជាមួយលោកគ្រូអ្នកគ្រូក្នុងនាមជាមេដឹកនាំលើអ្នកសិក្សា ធ្វើយ៉ាងណាដើម្បីបង្កើនការចូលរួមពីមាតាបិតាសិស្ស និងពីសហគមន៍ ការវិភាគតួលេខមូលដ្ឋាន និងការអភិវឌ្ឍន៍គម្រោងកែលម្អសាលារៀន។

ក្នុងរយះពេលដែលចាប់ផ្តើមតាំងពីខែវិច្ឆិកាដល់ខែធ្នូ ២០១០ ក្រុមត្រួតពិនិត្យការងារបានចុះទស្សនកិច្ចអ្នកចាត់ការសាលារៀនចំនួន ៤៣០ នាក់ (រឺប្រហែលជា ៨២ % នៃនាយកសាលា និងនាយករង ដែលបានមកចូលរួមក្នុងសិក្ខាសាលានេះ) ។ លទ្ធផលបង្ហាញឱ្យឃើញ ថាអ្នកដែលបានមកចូលរួមក្នុងសិក្ខាសាលានេះសុទ្ធតែមានស្នាដៃអនុវត្តការងារបានល្អប្រសើរបើប្រៀបធៀបទៅនឹងការវាយតំលៃដែលផ្អែកលើព័ត៌មានបឋម ។ តាមរយះការពិភាក្សាជាក្រុម ជាមួយគ្រូបង្រៀន សិស្ស និងតំណាងសហគមន៍ ក្រុមត្រួតពិនិត្យវាយតំលៃ បានឱ្យដឹងថាអ្នកគ្រប់គ្រងសាលារៀនសុទ្ធតែស្តែងចេញឱ្យឃើញនូវទំនាក់ ទំនងរបស់គេជាមួយគ្រូបង្រៀន សិស្ស ឪពុកម្តាយសិស្ស និង សហគមន៍សុទ្ធតែមានការកែប្រែបានល្អជាវិជ្ជមាន។







## សមាសភាគ ៤ ៖ បង្កើនបរិបទលើការអប់រំដែលពាក់ព័ន្ធនឹងជីវិតរស់នៅ

ជំហានសំខាន់តំបូងក្នុងការអនុវត្តន៍កម្មវិធីសាកល្បងបំណិនជីវិតមូលដ្ឋានដែលធ្វើឡើងនៅត្រីមាសនេះ គឺការរៀបចំឱ្យហើយនៅឆ្នាំនេះ។ ចំពោះវិសមកាលរដូវក្តៅ គឺយកពេលនេះសម្រាប់ការរៀបចំសម្ភារៈបណ្តុះបណ្តាលការតម្រង់ទិសដល់សាលាមធ្យមសិក្សាទាំងឡាយ ដែលបានកំណត់ជ្រើសរើស ហើយតើនរណាដែលនឹងត្រូវចូលរួម ដើម្បីធានាឱ្យបានថាកម្មវិធីបំណិនជីវិតនេះត្រូវបានសហការចូលរួមពីបុគ្គលិករៀបចំផែនការសាលារៀន។ ក្នុងខែកញ្ញា ការពិនិត្យឡើងវិញនូវដំណើរការដែលបានអនុវត្ត បានឆ្លុះបញ្ចាំងឱ្យឃើញនូវការបង្កើតឯកសារមេរៀនពីព្រោះរាល់ការឆ្លើយតបនិងការអង្កេតហ្មត់ចត់របស់ក្រុមបច្ចេកទេស បង្ហាញឱ្យឃើញថា ខ្លឹមសារលើបញ្ហាទាំងនេះ គឺសុទ្ធតែជាមហិច្ឆិតាចង់បានសម្រាប់ដំណាក់ការដំបូងនៃការចាប់ផ្តើមកម្មវិធីបំណិនជីវិត។ ដូចនេះហើយបានជាក្រុមការងារពិសេសមួយត្រូវបានបង្កើតឡើងដោយមានបុគ្គលិកមកពីគម្រោង IBEC និងនាយកដ្ឋាននានានៃក្រសួងអប់រំយុវជន និងកីឡា ដើម្បីពិនិត្យ និងកែសម្រួលសម្ភារៈដែលមានស្រាប់ដើម្បីធ្វើឱ្យការប្រើប្រាស់រិតតែមានមេត្រីភាពឡើង។

ដើម្បីកុំឱ្យកម្មវិធីនេះយឺតពេលក្រុម IBEC បានប្រតិបត្តិដោយជោគជ័យលើការដាក់ផែនការនៃវគ្គតម្រង់ទិសដែលជាគន្លឹះសំខាន់សម្រាប់អ្នកពាក់ព័ន្ធ និងអ្នកបណ្តុះបណ្តាលនៅខែតុលា ដើម្បីឱ្យវគ្គនេះអាចចាប់ផ្តើមនៅតាមសាលាសាកល្បងនាត្រីមាសទីមួយនៃឆ្នាំសិក្សានេះ។ ការងារនេះសំខាន់ណាស់ពីព្រោះវាជួយឱ្យសាលាចាប់ផ្តើមអនុវត្តនូវសកម្មភាពការងារបំណិនជីវិតមួយចំនួននៅតាមសាលារបស់គេ ដែលបានគ្រោងទុកលើផែនការកែលម្អសាលារៀនដោយមិនពន្យាពេលយូរឡើយ។ ជាសរុបគម្រោង IBECបានបណ្តុះបណ្តាលបុគ្គលិកសាលាចំនួន ៦៣៨ នាក់ ក្នុងការអនុវត្តន៍ការងារបំណិនជីវិត ដោយរួមមាន គ្រូមធ្យមសិក្សាបឋមភូមិ ចំនួន ៣១៨ នាក់ គ្រូបឋមសិក្សាចំនួន ២០៧ នាក់ និងនាយកសាលាចំនួន ៩៩ នាក់។ ទាំងនេះអាចនឹងជួយដល់សកម្មភាពការងារបំណិនជីវិតចំនួន ៤៩២ ដែលធ្វើនៅតាមសាលាចំនួន ១៧២ (ក្នុងនោះមានសាលាបឋមសិក្សាចំនួន ៩៩ និងសាលមធ្យមសិក្សាចំនួន ៧៣) ។

សកម្មភាពនៃគម្រោង IBEC សំខាន់ៗផ្សេងទៀតក៏ធ្វើឡើងនៅត្រីមាសនេះដែរ។ កិច្ចអន្តរាគមន៍បណ្តុះបណ្តាលគ្រូគឺផ្តោតទៅលើសាលាថ្មីៗទាំងកម្រិតបឋមនិងមធ្យមសិក្សា។ គម្រោងបានបណ្តុះគ្រូនៅកម្រិតបឋមសិក្សាចំនួន ១៥៤ នាក់ និងគ្រូនៅកម្រិតមធ្យមសិក្សាចំនួន ៤៤៦ នាក់ ជាសរុប ម្រោងបានបណ្តុះបណ្តាលគ្រូចំនួន ៦០០ នាក់។ គ្រូទាំងនេះទទួលបាននូវការណែនាំស្តីពីគោលគំនិតនៃសាលាកុមារមេត្រី និងគោលនយោបាយរបស់ក្រសួងលើវិស័យនេះ។ វិធីសាស្រ្តក្នុងការបង្រៀន ដូចជាការសិក្សាតាមបែបសហការត្រូវបានលើកឡើងដើម្បីធ្វើយ៉ាងណាឱ្យលោកគ្រូអ្នកគ្រូមានទំនុកចិត្តក្នុងការប្រើប្រាស់តាមយុទ្ធវិធីផ្សេងៗ ដើម្បីជំរុញដល់ការសិក្សារបស់សិស្ស។

ក្រុម IT នៃគម្រោង IBEC ក្នុងត្រីមាសនេះ បានផ្តោតលើការជ្រើសរើសសាលាថ្មីដើម្បីរៀបចំបន្ទប់កុំព្យូទ័រ ដោយមានក្រុមការងារខេត្ត (ប្រើគោលការលក្ខណៈជាស្តង់ដា) ចាត់ចែងបញ្ជាទិញសម្ភារៈ និងចាប់ផ្តើមតំឡើងឱ្យបាន ៥សាលានៅបំណាច់ត្រីមាសនេះ។ គម្រោងIBECមានផែនការជួយធ្វើយ៉ាងណាឱ្យតំឡើងបានបន្ទប់កុំព្យូទ័រថ្មីជាសរុបចំនួន៧នៅឆ្នាំនេះ។ គម្រោងក៏មានផែនការពង្រីកនូវទំហំនៃការប្រើប្រាស់បន្ទប់កុំព្យូទ័រនេះពី ១៣ ទៅ ១៥-១៩ គ្រឿង យោងតាមសំណើពី MoEYS។ ថវិកាសម្រាប់ចាយវាយដោយប្រើថាមពលនៃពន្លឺព្រះអាទិត្យអាចត្រូវបានបំលែងឱ្យទៅជាបន្ទប់ធំៗបាន។ ជំនួយថវិកាសរុបលើផ្នែកនេះ ដែលឧបត្ថម្ភដោយ USAID សង្ឃឹមថានឹងអាចធ្វើបានដល់ទៅ ២៦ បន្ទប់កុំព្យូទ័រក្នុងឆ្នាំនេះ ដែលអាចឱ្យសិស្សចូលប្រើប្រាស់បានប្រហែលជាចំនួន ១៨ ២២៧ នាក់ ។